# មេរៀនទី ១០២៖ យ៉ូណាថានជាស់តឿនដាវីឌ

១ សាំយូអែល ១៨៖ ១-៤; ១៩៖១-៧; ២០៖១-៤២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/CzzW1KnG_ul

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/uIPb11NCf7g

**គោលបំណង៖ ព្រះប្រទានមិត្តសម្លាញ់។**

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៥៖១៣** *"គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិត ជំនួសពួកសំឡាញ់របស់ខ្លួននោះទេ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយេស៊ូវល្អក្រៃលែង https://youtu.be/uFsMi06lhvE

២. ព្រះយេស៊ូវស្រលាញ់ខ្ញុំណាស់ https://youtu.be/R4MEw0jzZ_E

៣. នៅកន្លែងនេះមានក្តីស្រឡាញ់ https://youtu.be/iUGQmu1AmLI

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ចងចាំឈ្មោះ»



១. ឲ្យកុមារអង្គុយជារង្វង់

២. ជ្រើសរើសកុមារម្នាក់ធ្វើជាអ្នកចាំទី ដោយឲ្យគាត់ឈរនៅចំកណ្តាលរង្វង់។ ឲ្យដបទឹកទទេ ឬក៏មូល ក្រដាសកាសែតទៅអ្នកចាំទី ដើម្បីទុកវាយអ្នកដែលគេហៅឈ្មោះនោះ។

៣. អ្នកចាំទីនឹងត្រូវជ្រើសរើសកុមារណាម្នាក់ ហើយសួរគាត់ពីឈ្មោះអ្នកដែលគាត់ចង់ឲ្យអ្នកចាំទីវ៉ៃ។

៤. ហើយអ្នកចាំទីត្រូវរត់ទៅវាយកុមារ ដែលត្រូវបានគេហៅឈ្មោះនោះ។ ហើយកុមារដែលត្រូវគេហៅឈ្មោះត្រូវហៅឈ្មោះកុមារផ្សេងទៀត។ ប្រសិនបើអ្នកចាំទីប៉ះគាត់ មុនពេលដែលគាត់ហៅឈ្មោះកុមារផ្សេងទៀត គាត់ត្រូវធ្វើជាអ្នកចាំទីវិញម្តង។ ប្រសិនបើអ្នកចាំទីមិនស្គាល់ឈ្មោះរបស់អ្នកនោះទេ គាត់ត្រូវបន្តចាំទីទៀត។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកគេត្រូវចងចាំឈ្មោះនរណាម្នាក់ ប្រសិនបើគាត់ចង់ក្លាយជាមិត្តល្អជាមួយពួកគេ។

### ៤. ការណែនាំមេរៀន

តើប្អូនៗណាខ្លះមានមិត្តភក្តិចំនួន១០នាក់? ហើយប្អូនៗណាខ្លះមានមិត្តភក្តិចំនួន៩នាក់? ៨នាក់? ៧នាក់? ៦នាក់?៥នាក់? តើអ្នកណាដែលអត់មានមិត្តភក្តិសោះនោះ? តើប្អូនមានអារម្មណ៍ដូចម្តេចបើប្អូនទៅរៀនតែអត់មានអ្នកណាចង់ធ្វើជាមិត្តរបស់ប្អូននោះ? ប្អូនអត់មានអ្នកណាលេងជាមួយ ហើយអត់មានអ្នកណានិយាយរក! តើវាមិនកំសត់ពេកទេឬ? ព្រះដឹងថា វាគឺមានសារៈ សំខាន់ណាស់សម្រាប់យើង ដែលត្រូវមានមិត្តភក្តិនោះ។ តាមពិត ព្រះយេស៊ូវយាងមកដើម្បីសង្គ្រោះយើង និងដើម្បីធ្វើជាមិត្ត

សម្លាញ់របស់យើង។ ថ្ងៃនេះយើង នឹងរៀនពីមនុស្ស២នាក់នៅក្នុងព្រះព្រះគម្ពីរ ដែលចេះជួយគ្នាទៅវិញទៅមក ពីព្រោះពួកគេជាមិត្តសម្លាញ់នឹងគ្នា។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ ស្តេចសូលមានកូនប្រុសម្នាក់ឈ្មោះយ៉ូណាថាន។ ថ្ងៃមួយ យ៉ូណាថានបានជួបជាមួយដាវីឌ ដែលជាអ្នកសំលាប់កូលីយ៉ាត។ ពួកគេចូលចិត្តគ្នាតាំងពីថ្ងៃជួបគ្នាដំបូង ហើយពួកគេ បានសន្យាធ្វើជាមិត្តសម្លាញ់នឹងគ្នារហូតទៅ។ ដើម្បីបង្ហាញពីមិត្តភាពរបស់គាត់ យ៉ូណាថានបានឲ្យសម្លៀកបំពាក់ ដាវ និងធ្នូរបស់គាត់ឲ្យទៅដាវីឌ។

ដាវីឌ និងយ៉ូណាថានពួកគាត់ទាំងពីរជាទាហ៊ានក្លាហាន។ ពួកគាត់ទាំងពីរបានប្រឆាំងជាមួយស្តេចសូល ដែលជាឪពុករបស់យ៉ូណាថាន។ ដាវីឌបានក្លាយជាអ្នកចម្បាំងដ៏ល្អម្នាក់ ដែលប្រជាជនស្រឡាញ់គាត់ជាងសូល។ នោះធ្វើឲ្យសូលខឹង។ ហើយសូលចង់សម្លាប់ដាវីឌ។

យ៉ូណាថានប្រាប់ស្តេចសូលថា ការសម្លាប់ដាវីឌគឺខុស។ គាត់បានរំឭកឪពុកគាត់ថា ដាវីឌបានជួយគាត់ឈ្នះការប្រយុទ្ធជាច្រើន ហើយគឺដាវីឌនេះហើយដែលបានសម្លាប់កូលីយ៉ាត។ សូលសម្រេចចិត្តមិនសម្លាប់ដាវីឌ។ ប៉ុន្តែក្រោយមកកំហឹង និងការច្រណែនរបស់គាត់វាកាន់តែខ្លាំងឡើងៗ ក្រោយមកគាត់ក៏ចេញបញ្ជាម្តងទៀតឲ្យសម្លាប់ដាវីឌ។ គាត់ថែមទាំងបានគប់លំពែងដាក់យ៉ូណាថាន ដែលជាកូនប្រុសរបស់គាត់ នៅពេលគាត់ដឹងថាយ៉ូណាថានកំពុងជួយដាវីឌ។ យ៉ូណាថានបានដាស់តឿនដាវីឌ ទោះប្បីគាត់ដឹងថាឪពុករបស់គាត់ខឹងខ្លាំងដល់ថ្នាក់អាចសម្លាប់គាត់ក៏ដោយ តែគាត់នៅតែជួយដាវីឌឲ្យរត់ទៅកន្លែងដែលមានសុវត្ថិភាព។ ប៉ុន្តែមុនពេលនោះពួកគេទាំងពីរបានសន្យាថានឹងធ្វើជាមិត្តនឹងគ្នារហូត។ យ៉ូណាថានជា មិត្តល្អសំរាប់ដាវីឌ ពីព្រោះគាត់បានប្រថុយជីវិតរបស់គាត់ដើម្បីជួយដាវីឌ។

មិត្តភាពរបស់ដាវីឌ និងយ៉ូណាថានពិតជារឹងមាំពីព្រោះពួកគេស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។ មិត្តភាពពិតប្រាកដអាចកើតបានក៏ដោយសារតែការប្រឹងប្រែងរបស់ភាគីសងខាង។ អ្នកត្រូវយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។ ព្រះបានប្រទានមិត្តសម្លាញ់ដល់យើង ដូចដែលព្រះអង្គបាន ប្រទានឲ្យយ៉ូណាថាន និងដាវីឌដែរ។ តើអ្នកបានយកចិត្តទុកដាក់ចំពោះមិត្តសម្លាញ់របស់អ្នកដែរឬទេ? សូមអរព្រះគុណព្រះ ដែលទ្រង់បានប្រទានមិត្តសម្លាញ់ឲ្យយើង។

## ៦. សំនួរពិភាក្សា

១. តើមិត្តសម្លាញ់ពីរនាក់នៅក្នុងរឿងព្រះគម្ពីរនៅថ្ងៃនេះមានឈ្មោះអ្វី? *(យ៉ូណាថាន និងដាវីឌ)*

២. តើស្តេចសូលជានរណា? *(ជាឪពុករបស់យ៉ូណាថាន)*

៣. ហេតុអីបានជាស្តេចសូលចង់សម្លាប់ដាវីឌ? *(ពីព្រោះប្រជាជនស្រឡាញ់ដាវីឌជាងគាត់)*

៤. តើ យ៉ូណាថាន បានបង្ហាញមិត្តភាពរបស់គាត់ទៅកាន់ដាវីឌដោយរបៀបណា?
*(គាត់ស្ទើរតែត្រូវឪពុកសម្លាប់ដោយសារ តែគាត់ព្យាយាមជួយដាវីឌ)*

៥. តើអ្នកមានចិត្តចង់ធ្វើអ្វីខ្លះសំរាប់មិត្តសម្លាញ់របស់អ្នក?
*(ចែករំលែកក្តីស្រឡាញ់ មានសណ្តានចិត្តល្អ ។ល។)*

## ៧. ល្បែងកំសាន្ត «ដូចគ្នា»



១.ឲ្យកុមារទាំងអស់ក្រោកឈរឡើង ហើយនៅពេលដែលគ្រូស្រែកពាក្យណាមួយកុមារត្រូវរត់រកអ្នកណាដែលមានភាពដូចគ្នានោះ។ឧទាហរណ៍៖

“អាយុដូចគ្នា” បន្ទាប់មកកុមារដែលមានអាយុដូចគ្នាត្រូវរត់រកគ្នា។ ក្រុម ណាដែលមានគ្នាច្រើនជាងគេ ក្រុមនោះជាអ្នកឈ្នះ។

២. ពាក្យផ្សេងទៀត៖ ភេទដូចគ្នា អាយុដូចគ្នា ថ្នាក់ដូចគ្នា ខោខ្លីដូចគ្នា។ល។

៣. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា នៅពេលដែលពួកគេមានភាពដូចគ្នាច្រើនវានឹងជួយពួកគេឲ្យក្លាយជាមិត្តជិតស្និទ្ធនិងល្អជាងមុន។

## ៨. ខគម្ពីរចងចាំ

**យ៉ូហាន ១៥៖១៣** *“គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណា នឹងប្តូរជីវិតជំនួសពួកសំឡាញ់របស់ខ្លួននោះទេ។”*

## ៩. ហត្ថកម្ម «កងដៃមិត្តភាព»

សម្ភារៈដែលត្រូវការ៖ ទុយោ (ចំរុះពណ៌) កន្ត្រៃ ខ្សែ





១. កាត់ទុយោជាកំណាត់តូចៗ

២. កាត់ខ្សែរំជុំវិញកដៃរបស់ក្មេងៗ (ធ្វើវាឲ្យវែងជាងទុយោដូច្នេះយើងអាចចងវាបាន)។

៣. ស៊កកំណាត់ទុយោដាក់ជាមួយខ្សែ ។

៤. ចងចុងខ្សែទាំងសងខាងឲ្យជាប់គ្នា។

៥. ដូរខ្សែដៃរបស់អ្នកជាមួយមិត្តភក្តិរបស់អ្នក ដើម្បីបង្ហាញថាអ្នកយកចិត្តទុកដាក់ចំពោះមិត្តភក្តិរបស់គេប៉ុនណា!

៦. បើអ្នកមានពេលធ្វើខ្សែដៃឲ្យបានច្រើនជាងនេះដើម្បីចែកឲ្យមិត្តភក្តិផ្សេងៗទៀត។

៧. បន្ទាប់ពីកុមារចែកខ្សែដៃរួចហើយ សូមពន្យល់កុមារថាព្រះបានប្រទានមិត្តសម្លាញ់ឲ្យដល់ពួកគេ។ យើងត្រូវតែធ្វើល្អជាមួយមិត្តភក្តិរបស់ពួកយើង គឺដោយការចេះយកចិត្តទុកដាក់ ចិត្តល្អ និងចេះជួយគ្នា!

## ១០. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវគឺជាមិត្តសម្លាញ់ដែលមានភក្តីភាព ព្រោះព្រះអង្គបានសុគត់លើឈើឆ្កាងសំរាប់យើងគ្រប់គ្នា ព្រះអង្គនឹងសព្វព្រះទ័យបើយើងស្មោះត្រង់ជាមួយមិត្តភក្តិរបស់យើងនៅពេលដែលវាពិបាកនឹងធ្វើ។ សូមអាន **១ សាំយូអែល ២០៖២៨-៣២**។ តើយ៉ូណាថានបានលះបង់អ្វីដើម្បីរក្សាចិត្តស្មោះត្រង់ជាមួយដាវីឌ? តើអ្វីខ្លះដែលអ្នកធ្លាប់លះបង់ដើម្បីរក្សាភាពស្មោះត្រង់ជាមួយមិត្តភក្តិរបស់អ្នក? តើនៅក្នុងស្ថានភាពបែបណាដែលអ្នកជ្រើសរើសយកភាពស្មោះត្រង់លើសអ្វីៗដែលអ្នកប្រាថ្នាចង់បាន? ព្រះចង់ឲ្យយើងស្មោះត្រង់នឹងមិត្តភក្តិរបស់យើង។ សូមតាំងចិត្តថ្ងៃនេះដើម្បីរក្សាភក្តីភាពចំពោះមិត្តភក្តិរបស់អ្នកក្នុងរបៀបដែលគោរពដល់ព្រះនិងមិត្តភក្តិរបស់អ្នក។